ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ទទួលជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ (“កិច្ចប្រជុំ”) តាមរយៈ **អ៊ីម៉ែល** ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦** ចាប់ពីម៉ោង **១៣:០០** ដល់ម៉ោង **១៥:០០ រសៀល** (ម៉ោងនៅភ្នំពេញ) តាមរបៀបវារៈ៖

- អនុម័ត និងទទួលស្គាល់លើការតែងតាំងបេក្ខភាពមួយរូប មកពី COFIBRED ជាតំណាងភាគហ៊ុនិកថ្មី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោកស្រី Quitterie De La Rochefordière។

ភាគហ៊ុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក**នៅកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥** នឹងទទួលបានលិខិតអញ្ជើញ ឯកសារគាំទ្រ សេចក្តីណែនាំការបោះឆ្នោតតាមប្រព័ន្ធ e-Voting លិខិតប្រគល់សិទ្ធិ និង QR Code សម្រាប់ការបោះឆ្នោត ដែលធនាគារ អេស៊ីលីដា នឹងផ្ញើជូនតាមរយៈអ៊ីម៉ែល។ ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ អាចផ្តល់សិទ្ធិប្រទានទៅឱ្យអ្នកតំណាងណាម្នាក់ ដើម្បីចូលរួម និងបោះឆ្នោតជំនួសបាន។ ភាគហ៊ុនិក ឬអ្នកទទួលសិទ្ធិត្រូវផ្ញើលិខិតប្រគល់សិទ្ធិច្បាប់ដើមមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា យ៉ាងយូរត្រឹម**ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦**។

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

- ធនាគារ អេស៊ីលីដា នឹងផ្ញើ QR Code សម្រាប់ការបោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗ តាមរយៈអ៊ីម៉ែល ចាប់ពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ ម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ ម៉ោង ១២:០០ ថ្ងៃត្រង់ (ម៉ោងនៅភ្នំពេញ)។
- ភាគហ៊ុនិកម្នាក់ៗត្រូវបោះឆ្នោតនៅ**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦** ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង **១៣:០០** ដល់ម៉ោង **១៥:០០ រសៀល** (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code សម្រាប់ការបោះឆ្នោត (សូមពិនិត្យសេចក្តីណែនាំការបោះឆ្នោតតាមប្រព័ន្ធ e-Voting ដែលនឹងផ្ញើជូនជាមួយ QR Code)។

**បញ្ជាក់៖**

- ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនៅ**ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥**។
- ភាគហ៊ុនិកដែល **លក់** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥** គឺ **នៅតែមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាត។
- ភាគហ៊ុនិកដែល **ទិញ** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥** គឺ **មិនមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតឡើយ។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំនេះ តាមរយៈអ៊ីម៉ែលតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (ភ្នាក់ងារ RTP) របស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  - ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  - អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  - ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  - អ៊ីម៉ែល: op.rtp@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃសុក្រ ១៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**